# ព្រឹត្តិបត្រប្រចាំត្រីមាសទី២

*ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប*

ខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២១


## បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក) ជាអង្គការឯករាជ្យប្រមូលផ្តុំអ្នកផ្គត់ផ្គង់ទឹកស្អាតទាំងអស់នៅកម្ពុជា ដើម្បីបំរើផលប្រយោជន៍រួមរបស់សមាជិកសមាគមដោយមិនស្វែងរកប្រាក់ចំណេញជាឯកជន និងមិនចំណុះឱ្យគណបក្សនយោបាយ។

សមាគមត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃ នៅថ្ងៃទី៦ ខែសីហា ឆ្នាំ០១២។ សមាគមមានគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់នៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

ទស្សនៈវិស័យរបស់សមាគមគឺ ផ្តល់នូវសេវាកម្មផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនប្រកបដោយគុណភាព និងអនាម័យស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ នៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានសមាជិកសរុប **២៨៩ស្ថានីយ និងក្រុមហ៊ុន**។ ក្នុងនោះមាន ២៦០ ជាស្ថានីយផ្គត់ផ្គង់ទឹកស្អាតនៅទូទាំង ២៣រាជធានីខេត្ត-ក្រុង និង២៩ ជាក្រុមហ៊ុនផ្គត់ផ្គង់សម្ភារៈលើវិស័យទឹកស្អាត។

## ការចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

### *១. ការរៃអង្គាសប្រាក់សម្រាប់ជួយដល់ប្រជាពលរដ្ឋក្នុងតំបន់បិទខ្ទប់*

នៅព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១ ពិធីប្រគល់-ទទួលប្រាក់ដែលទទួលបានពីសមាជិកសមាគម សម្រាប់ជួយដល់ប្រជាពលរដ្ឋដែលរងគ្រោះក្នុងតំបន់បិទខ្ទប់មានប្រាក់ចំនួន១០.៨៧៥ (ដប់ពាន់ប្រាំបីរយចិតសិបប្រាំ) ដុល្លារអាមេរិក និង២.២៦៣.៤០០ (ពីរលាន ពីររយហុកសិបបីពាន់ បួនរយ) រៀល ត្រូវបានរៀបចំឡើងរវាង ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលោក **ឡេង ឡៅ** ប្រធានសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) នៅទីស្តីការក្រសួង។

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី** បានសម្តែងអំណរគុណ និងកោតសរសើរចំពោះស្មារតីចូលរួមទទួលខុសត្រូវសង្គមរបស់សមាជិកសមាគមសម្រាប់ការជួយទៅដល់ប្រជាពលរដ្ឋដែលរងគ្រោះក្នុងតំបន់បិទខ្ទប់ដោយសារជំងឺកូវីដ-១៩។ ប្រាក់ដែលទទួលបានក្រសួងនឹងចាត់ចែងបន្តទៅតាមតំបន់គោលដៅដែលក្រសួងធ្លាប់បានធ្វើរួចមកហើយដូចជា ជាមួយសាលារាជធានីភ្នំពេញនារយៈពេលថ្មីៗកន្លងមកនេះជាដើម។ តទៅទំព័រទី៣)



*រូបថតជុំគ្នាក្រោយពេល ប្រគល់-ទទួលប្រាក់នៅទីស្តីការក្រសួង*



មជ្ឈមណ្ឌលភ្នំពេញ(ភ្នំពេញ សិនធើរ) អគារ□ ជាន់ទី២ បន្ទប់លេខ២២៦៩, វិថី សម្តេចសុធារស កែងវិថីព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន រាជធានីភ្នំពេញ ០១៧ ៧៩៩ ៣៣៧/ ០៧០ ៧៩៩ ៣៣៧ info@cwa.org.kh www.cwa.org.kh

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ៨៤០ MISTI / ២០២១

# លិខិតថ្លែងអំណរគុណ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
សូមថ្លែងអំណរគុណ

**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)**

បានផ្តល់អំណោយជាថវិកាចំនួន ១០ ៨៧៥ ដុល្លារអាមេរិក និង ២ ២៦៣ ៤០០ រៀល ដល់រាជរដ្ឋាភិបាលតាមរយៈក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ប្រើប្រាស់ក្នុងសភាពការណ៍បន្ទាន់ និងចាំបាច់នៃការទប់ស្កាត់នូវជំងឺរាតត្បាតកូវីដ-១៩ (Covid-19)។

ថ្ងៃ សុក្រ ៩ រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

(តពីទំព័រទី១)

លោក **ឡេង ឡៅ** ប្រធានសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានមានប្រសាសន៍ថា ដើម្បីជួយរំលែកការលំបាករបស់រាជរដ្ឋាភិបាល សមាគមបានផ្តួចផ្តើមរៃអង្គាសប្រាក់តាមគោលការណ៍ស្ម័គ្រចិត្តក្នុងក្របខណ្ឌសមាគមចាប់ពីថ្ងៃទី១៣ ខែមេសា រហូតដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ។ ជាលទ្ធផលសមាគមទទួលបានការគាំទ្រជាច្រើនពីសមាជិករបស់ខ្លួនដើម្បីរួមចំណែកក្នុងកម្មវិធីជំនួយសង្គ្រោះបន្ទាន់ជូនដល់ប្រជាពលរដ្ឋងាយរងគ្រោះ និងជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃក្នុងតំបន់បិទខ្ទប់។

ជាមួយគ្នានេះលោកប្រធានបានស្នើសុំទៅក្រសួងចំនួនពីរចំណុចដូចខាងក្រោម៖

- សូមឱ្យ**ក្រសួង**ជួយពន្លឿនក្នុងការផ្តល់អាជ្ញាបណ្ណជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតជាសមាជិកសមាគមដែលបានដាក់ពាក្យរួចហើយ។
- សូមឱ្យ**ក្រសួង**មេត្តាជួយកៀរគរទុនវិនិយោគបន្ថែមលើវិស័យទឹកស្អាតឯកជនក្នុងភាពជាអំណោយ ឬកម្ចីដែលមានអត្រាការប្រាក់ទាប និងមានរយៈពេលវែង។

ជាការឆ្លើយតប **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានធ្វើប្រតិភូអំណាចក្នុងការចេញអាជ្ញាបណ្ណនេះមកនៅត្រឹម **រដ្ឋលេខាធិការ** ប៉ុណ្ណោះ ដើម្បីពន្លឿនការងារនេះ ហើយ**ក្រសួង** នៅតែបន្តខិតខំស្វែងរកទុនពីដៃគូអភិវឌ្ឍន៍បន្ថែមទៀត។

## ២. ការរៃអង្គាសជាសម្ភារៈប្រើប្រាស់ពីក្រុមហ៊ុនដែលជាសមាជិក

ជាការឆ្លើយតបទៅនឹងសំណើររបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល ស្តីពីការស្នើសុំជួយជាសម្ភារៈសម្រាប់អប់រំ និងវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជូនដល់មណ្ឌលចត្តាឡីស័កក្នុងខេត្តកណ្តាល **សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** បានរៃអង្គាសជាសម្ភារៈប្រើប្រាស់ពីក្រុមហ៊ុន ដែលជាសមាជិករបស់ខ្លួនតាមគោលការណ៍ស្ម័គ្រចិត្តក្នុងក្របខណ្ឌសមាជិកសមាគម ដូចជា សាប៊ូ ម៉ាស អាល់កុល និងទឹកសុទ្ធ។ ជាលទ្ធផលយើងទទួលបានការឧបត្ថម្ភពីក្រុមហ៊ុនចំនួនប្រាំគឺ៖ ១.ក្រុមហ៊ុន ធីស៊ីយូប៉ូលី អិនធើប្រាយ ម៉ាសចំនួន ១០០០០ម៉ាស់ និងទឹកសុទ្ធវីតាល់ចំនួន ២៤០០ដប ២. ក្រុមហ៊ុន រ៉ធើម៉ិចថេកណូឡូជី ម៉ាសចំនួន ១៥០ម៉ាស ៣. ក្រុមហ៊ុន ភ្នំពេញប្លាស្ទិច ប្រូដាក់ ម៉ាសចំនួន ៧៥០០ម៉ាស់ និងទឹកសុទ្ធវីតាល់ចំនួន ៩៦០ដប ៤. ក្រុមហ៊ុន ឥន្ទធនូខេមបូឌាត្រេឌីង ម៉ាសចំនួន ១០០០០ម៉ាស ៥. ក្រុមហ៊ុន ខេស៊ីអអាយ អ៊ិនធើណេសិនណលខូអបកើរេសិន ឯ.ក ដែលសម្រាប់លាងដៃចំនួន ១០០ដប (៥០ដបធំ និង ៥០ដបតូច) និង**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** សាប៊ូលាងដៃ ៤០ដុំ។

សម្ភារៈដែលទទួលបានពីការឧបត្ថម្ភរបស់សមាជិកទាំងអស់សមាគមបានប្រគល់ជូនទៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាលដើម្បីចាត់ចែងបន្តទៅតាមមណ្ឌលចត្តាឡីស័កនានាក្នុងខេតកណ្តាល។


មជ្ឈមណ្ឌលភ្នំពេញ(ភ្នំពេញ សិនធើរ) អគារ□ ជាន់ទី២ បន្ទប់លេខ២៦៩, វិថី សម្តេចសុធារស កែងវិថីព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន រាជធានីភ្នំពេញ ០១៧ ៧៩៩ ៣៣៧/ ០៧០ ៧៩៩ ៣៣៧ info@cwa.org.kh www.cwa.org.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**
មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល
លេខៈ ០០៨/២១ ម.អ.ជ/ក.ណ

# លិខិតថ្លែងអំណរគុណ
## មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **លោកប្រធាន**
**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ដែលបានចូលរួមជួយឧបត្ថម្ភជាសម្ភារ ដើម្បីរួមចំណែក
ក្នុងយុទ្ធនាការអប់រំ និងផ្សព្វផ្សាយពីវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងខេត្តកណ្តាល។
សូម **លោកប្រធានសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា** ព្រមទាំងសហការី ជួបប្រទះនឹងសុខភាពល្អ
ជោគជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
កណ្តាល, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១
**ប្រធានមន្ទីរ**

**ឌី ចាន់ធី**


មជ្ឈមណ្ឌលភ្នំពេញ(ភ្នំពេញ សិនធើរ) អគារ□ ជាន់ទី២ បន្ទប់លេខ២៦៩, វិថី សម្តេចសុធារស កែងវិថីព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន រាជធានីភ្នំពេញ ០១៧ ៧៩៩ ៣៣៧/ ០៧០ ៧៩៩ ៣៣៧ info@cwa.org.kh www.cwa.org.kh

# កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ នេះក្រុមប្រឹក្សាភិបាលបានរៀបចំកិច្ចប្រជុំចំនួន ៤ដង។

១. លើកទី១ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ក្នុងគោលបំណងដើម្បីធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីសមាគមនៅក្រសួងមហាផ្ទៃស្តីពីការទទួលស្គាល់ ប្រធាន អនុប្រធានហេរញ្ញិក និងសមាជិកក្រុមប្រឹក្សាភិបាលរបស់សមាគមតាមលទ្ធផលសន្និបាតសមាគម កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ និងអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរអាសយដ្ឋានទីស្នាក់ការសមាគមមកតាំងនៅអគារF ជាន់ទី២ បន្ទប់២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ ស្ថិតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ទន្ទឹមនេះក្រសួងមហាផ្ទៃស្នើឱ្យសមាគមរៀបចំលក្ខន្តិកៈឡើងវិញឱ្យស្របតាមបញ្ញត្តិមាត្រា៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ចំពោះបញ្ហានេះលោកមេធាវី **គិន ឈុនឡេង** បាននឹងកំពុងធ្វើការកែសម្រួលជាមួយមន្ត្រីបច្ចេកទេសរបស់ក្រសួងមហាផ្ទៃដើម្បីចុះឈ្មោះសមាគមជានីតិបុគ្គល។ លើសពីនេះកិច្ចប្រជុំក៏បានពិភាក្សាលើ «ការស្នើសុំឱ្យគិតថ្លៃអគ្គិសនីជាប្រាក់រៀល» ដែលជាសំណូមពររបស់សមាជិកសមាគម និងការប្តូរឈ្មោះអតីតប្រធានក្រុមប្រឹក្សា និងអតីតនាយកប្រតិបត្តិនៅអគ្គនាយកដ្ឋានពន្ធដារ។

២. លើកទី២ នៅថ្ងៃទី១០ និងទី១១ ខែមេសា ឆ្នាំ២០២១ ក្នុងគោលបំណងពិភាក្សាលើបញ្ជីឈ្មោះសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងក្រុមហ៊ុន ព្រមទាំងពិភាក្សាពីការចូលរួមរបស់សមាគមក្នុងការដោះស្រាយបញ្ហាកូវីដ-១៩ ដែលបង្កផលប៉ះពាល់ដល់អាជីវកម្មទឹកស្អាតតាមសហគមន៍។



កិច្ចប្រជុំតាមអនឡាញរបស់ក្រុមប្រឹក្សាភិបាល

៣. លើកទី៣ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ដើម្បីរាយការណ៍អំពីរបាយការណ៍រីកចម្រើន និងរបាយការហិរញ្ញវត្ថុ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ ផែនការសកម្មភាព និងគម្រោងថវិកាសម្រាប់ត្រីមាសទី២ ឆ្នាំ២០២១ និងការរៃអង្គាសប្រាក់ដើម្បីចូលរួមគាំទ្ររាជរដ្ឋាភិបាលតាមរយៈក្រសួងក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩។

៤. លើកទី៤ ធ្វើនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពអំពី ជំងឺកូវីដ-១៩ ជាពិសេសដើម្បីឆ្លើយតបទៅនឹង ស.ជ.ណ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្តីពីការរៀបចំតេស្តគុណភាពទឹកស្អាតតាមស្ថានីយ និងជជែកពិភាក្សាអំពីការប្រមូលប្រាក់បរិច្ចាករបស់សមាជិកដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការជួយជនរងគ្រោះដោយសារជំងឺកូវីដ-១៩ តាមរយៈក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ

នៅក្នុងត្រីមាសទី២នេះ ក្រោមកិច្ចសហការរវាងអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាបានចូលរួមផ្តល់វគ្គបណ្តុះបណ្តាលចំនួន២លើក៖

លើកទី១ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ វគ្គបណ្តុះបណ្តាលស្តីពី «យុទ្ធសាស្ត្រទីផ្សារសម្រាប់បង្កើនអតិថិជន» ក្រោមអធិបតីភាព ឯកឧត្តម **សយ ភារម្យ** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈ Videos Conference (កម្មវិធី ZOOM)។ កម្មវិធីនេះមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង មន្ទីរ ឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទាំង២៥ រាជធានី-ខេត្ត បុគ្គលិកសមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជនប្រមាណ ១៣៣នាក់។

លើកទី២ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ វគ្គបណ្តុះបណ្តាលស្តីពី «ការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតជាមួយអាជ្ញាធរឃុំ/សង្កាត់» ក្រោមអធិបតីភាពឯកឧត្តម **សយ ភីរម្យ** រដ្ឋលេខាធិការជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈ Videos Conference (កម្មវិធី ZOOM)។

កម្មវិធីនេះមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង មន្ទីរ ឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទាំង២៥ រាជធានី-ខេត្ត បុគ្គលិកសមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងសាធារណៈប្រមាណ ១៣៥នាក់។

## វគ្គបណ្តុះបណ្តាលសហការនឹងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ក្នុងត្រីមាសទី២ ឆ្នាំ២០២១ បុគ្គលិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាបានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពី «គោលការណ៍ណែនាំទូទៅនៃបទដ្ឋានបច្ចេកទេសអប្បបរមាសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខ្នាតតូច និងបទប្បញ្ញត្តិពាក់ព័ន្ធសេវាផ្គត់ផ្គង់ទឹកស្អាត» ចំនួន២លើក ដែលរៀបចំដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈអនឡាញ (ហ្សូម) ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុំ សុថា** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពស់ខ្ពង់របស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។



ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ បុគ្គលិកសមាគម បានចូលរួមវគ្គបណ្តុះបណ្តាលតាមរយៈអនឡាញលើប្រធានបទ «**ប្រព័ន្ធគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាត** (WSMS)» ដែលរៀបចំដោយនាយកដ្ឋានផែនការ និងគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## វគ្គបណ្តុះបណ្តាលរបស់សមាគម

សមាគមក៏បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន២ គឺ៖ ការប្រើប្រាស់បណ្តាញសង្គម តាមរយៈអនឡាញ លើកទី១ ធ្វើឡើងនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ មានអ្នកចូលរួមចំនួន ២៣នាក់ និងលើកទី២ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ មានអ្នកចូលរួមចំនួន១២នាក់ ក្រោមមាតិកាដូចខាងក្រោម៖ ១. ការប្រើប្រាស់ ហ្សូម ២. សុវត្ថិភាពក្នុងការប្រើប្រាស់ ហ្វេសប៊ុក និងឆាត ៣. ការប្រើប្រាស់ ស្កាយ (Skype) ៤. ការប្រើប្រាស់កម្មវិធីតេឡេក្រាម (Telegram)



មជ្ឈមណ្ឌលភ្នំពេញ(ភ្នំពេញ សិនធើរ) អគារ□ ជាន់ទី២ បន្ទប់លេខ២៦៩, វិថី សម្តេចសុធារស កែងវិថីព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន រាជធានីភ្នំពេញ ០១៧ ៧៩៩ ៣៣៧/ ០៧០ ៧៩៩ ៣៣៧ info@cwa.org.kh www.cwa.org.kh

## កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងត្រីមាសទី២ ឆ្នាំ២០២១ សមាគមទឹកអូស្ត្រាលី ត្រូវការជ្រើសរើសបេក្ខជនចំនួន ៥រូបពីប្រទេសកម្ពុជាដើម្បីចូលរួមក្នុងគម្រោង **ភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត** ដែលមានរយៈពេល ១២ខែ (អាហារូបករណ៍)។

ក្រោមកិច្ចសហការភាពជាដៃគូរវាងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងសមាគមទឹកអូស្ត្រាលី សមាគមបានជ្រើសរើសបេក្ខជនចំនួន ៤រូប ដើម្បីចូលរួមក្នុងគម្រោង ហើយក្នុងចំណោមបេក្ខជនទាំងប្រាំដែលបានជ្រើសរើសមាន ២រូបជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ២រូបមកពីអង្គការសង្គមស៊ីវិល និង១រូបទៀតជាបុគ្គលិកសមាគមត្រូវបានជ្រើសរើសដោយផ្ទាល់ពីសមាគមទឹកអូស្ត្រាលី។

**ភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត** នឹងចាប់ផ្តើមនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១។

## ការងារគម្រោង

### *១. ការគាំទ្រហិរញ្ញប្បទានលើបញ្ហាទឹក និងអនាម័យ WASH-FIN*

***ការរកប្រភពទុនកម្ចីសម្រាប់ការពង្រីកសេវាកម្មផ្គត់ផ្គង់ទឹកស្អាត***

សមាគមបានសម្របសម្រួលដល់សេវាករផ្គត់ផ្គង់ទឹកស្អាតដែលកំពុងដាក់ពាក្យស្នើសុំកម្ចី ២,៥០០,០០០ ដុល្លារពីធនាគារ Phillip Bank (១ស្ថានីយ)។

***ការកសាងសមត្ថភាពប្រតិបត្តិករ***

ក្នុងត្រីមាសទី២ គម្រោងបានធ្វើការវាយតម្លៃផ្នែកបច្ចេកទេសជូនដល់ ២ស្ថានីយ (ស្ថានីយទឹកស្អាតក្រាំងចេក និងស្ថានីយទឹកស្អាតចំការលើ)។ ជាលទ្ធផលរបាយការណ៍ទាំងពីរកំពុងព្រាង។

គម្រោងបានផ្តល់ឧបករណ៍តេស្តគុណភាពទឹក និងជ្យាតេស្តដល់ស្ថានីយចំនួន៨ ដែលអនុវត្តល្អក្នុងការប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

គម្រោងក៏បានផលិតវីដេអូស្តីពី «**ការតេស្តគុណភាពទឹកស្អាត**» និង«**ការប្រើប្រាស់ឧបករណ៍ជ្យាតេស្ត**» ព្រមទាំងផ្សព្វផ្សាយដល់សមាជិក និងចែករំលែកវីដេអូជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។




ការប្រគល់ឧបករណ៍ធ្វើតេស្តគុណភាពដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត



## ២. ការលើកកម្ពស់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅស្រុកសំបូរ (WaterAid)

### កិច្ចប្រជុំថ្នាក់ឃុំ

គម្រោងបានរៀបចំសម្របសម្រួលកិច្ចប្រជុំថ្នាក់ឃុំរវាងអាជ្ញាធរមូលដ្ឋាន (ស្រុកសំបូរ និងឃុំសំបូរ) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសំបូរ ដែលមានអ្នកចូលរួមសរុបមានចំនួន ១៩នាក់ (ស្រី៧នាក់) ជាមន្ត្រីសាលាស្រុកសំបូរ ក្រុមប្រឹក្សាឃុំសំបូរ មេភូមិ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត តំណាងអង្គការវ៉តធឺអេតកម្ពុជា និងតំណាងសមាគម។






### ទស្សនកិច្ចសិក្សា

ក្រោយបញ្ចប់កិច្ចប្រជុំថ្នាក់ឃុំ អ្នកចូលរួមទាំងអស់បានអញ្ជើញទៅទស្សនាប្រព័ន្ធសម្អាតទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គត់ទឹកស្អាតសំបូរដើម្បីស្វែងយល់បន្ថែមអំពីចង្វាក់ផលិតកម្មក្នុងការផលិតទឹកស្អាត។

### ការពង្រឹងសមត្ថភាព

ផ្តល់វគ្គបង្វឹកចំនួន ១វគ្គ ស្តីពី «ការតេស្តគុណភាពទឹកស្អាត» ដល់អាជ្ញាធរមូលដ្ឋាន (ថ្នាក់ស្រុក និងឃុំ) និងប្រតិបត្តិករ ដែលមានអ្នកចូលរួមសរុបមានចំនួន ១៩នាក់ (ស្រី៧នាក់)។


មជ្ឈមណ្ឌលភ្នំពេញ(ភ្នំពេញ សិនធើរ) អគារ□ ជាន់ទី២ បន្ទប់លេខ២២៩, វិថី សម្តេចសុធារស កែងវិថីព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន រាជធានីភ្នំពេញ ០១៧ ៧៩៩ ៣៣៧/ ០៧០ ៧៩៩ ៣៣៧ info@cwa.org.kh www.cwa.org.kh

## ការឆ្លុះបញ្ចាំង និងបិទបញ្ចប់គម្រោង

សមាគមបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោងចំនួន១ ដែលមានអ្នកចូលរួមចំនួន១៩ (ស្រី ៨នាក់) ដែលអញ្ជើញមកពីរដ្ឋបាលស្រុកសំបូរ ក្រុមប្រឹក្សាឃុំសំបូរ និងឃុំសណ្ដាន់ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទាំងពីរ។



កិច្ចប្រជុំឆ្លុះបញ្ចាំង និងបិទគម្រោង





គ្រួសារក្រីក្រដែលទទួលបានការតភ្ជាប់បណ្ដាញ

## ការឧបត្ថម្ភធន

ក្នុងត្រីមាសទី២ នេះគម្រោងបានផ្ដល់ការឧបត្ថម្ភធនលើការភ្ជាប់បណ្ដាញទឹកស្អាតដល់គ្រួសារក្រីក្រដែលមានប័ណ្ណក្រីក្រ កម្រិត១ និងកម្រិត២ ដល់គ្រួសារ ក្រីក្រសរុបចំនួន ១០៥គ្រួសារ (ប្រជាជនប្រមាណ ៥១៥នាក់) បានភ្ជាប់បណ្ដាញទឹកស្អាតប្រើប្រាស់។

## ៣. ការពង្រឹងគណនេយ្យភាពរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត (WaterAid)

ក្នុងត្រីមាសទី២ សមាគមបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយគម្រោងតាមអនឡាញជាមួយ៖

- ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនៅក្នុងខេត្តកំពង់ស្ពឺនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១
- ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនៅក្នុងខេត្តកណ្តាលនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១
- តំណាងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ឆ្នាំង តំណាងរដ្ឋបាលស្រុកកំពង់ត្រឡាច ស្រុកសាមគ្គីមានជ័យនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១
- តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងមន្ទីរ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង តំណាងរដ្ឋបាលស្រុកកណ្តាលស្ទឹង ស្រុកអង្គស្នួល ខេត្តកណ្តាល និង ស្រុកថ្ពង ខេត្តកំពង់ស្ពឺនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១។




*កិច្ចប្រជុំអនឡាញរវាងប្រតិបត្តិករ តំណាងមន្ទីរ តំណាងអង្គការវ៉តធឺអេត និងសមាគម*

លទ្ធផលនៃគម្រោងក្នុងត្រីមាសទី២

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសមាគម និងអង្គការវ៉តធឺអេត ជួបប្រជុំជាមួយ **ឯកឧត្តម** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាតដើម្បីធ្វើបទបង្ហាញអំពីគម្រោង និងស្វែងរកការគាំទ្រ។

- ក្រុមការងារបានប្រមូលទិន្នន័យដើមគ្រាពីប្រតិបត្តិករចំនួន ៨ស្ថានីយ
- ក្រុមការងារបានជំរុញឱ្យប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតធ្វើការផ្សព្វផ្សាយអំពីការឧបត្ថម្ភធនលើការភ្ជាប់បណ្តាញគ្រួសារក្រីក្រ
- ក្រុមការងារបានរៀបចំ និងធ្វើកិច្ចព្រមព្រៀងចូលរួមគម្រោងទៅប្រតិបត្តិករទាំង១០
- ក្រុមការងារបានរៀបចំរចនាខិត្តប័ណ្ណផ្សព្វផ្សាយសម្រាប់ប្រតិបត្តិករបានចំនួន ៤ស្ថានីយ
- ក្រុមការងារសមាគម និងអង្គការវ៉តធឺអេត បានផ្តួចផ្តើមរៀបចំឧបករណ៍ដាក់ពិន្ទុលើគណនេយ្យភាព (Scorecard) របស់ប្រតិបត្តិករ និងអាជ្ញាធរមូលដ្ឋានសម្រាប់ប្រើប្រាស់ក្នុងគម្រោង។



មជ្ឈមណ្ឌលភ្នំពេញ(ភ្នំពេញ សិនធើរ) អគារ□ ជាន់ទី២ បន្ទប់លេខ២៦៩, វិថី សម្តេចសុធារស កែងវិថីព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន រាជធានីភ្នំពេញ ០១៧ ៧៩៩ ៣៣៧/ ០៧០ ៧៩៩ ៣៣៧ info@cwa.org.kh www.cwa.org.kh

**៤. ការឧបត្ថម្ភធនលើថ្លៃភ្ជាប់សេវាទឹកស្អាតសម្រាប់គ្រួសារក្រីក្រ** ( EMW )

*លទ្ធផលនៃគម្រោង*

សមាគមបានបន្ថែមកិច្ចព្រមព្រៀងចំនួន១ទៀតជាមួយស្ថានីយទឹកស្អាត **ពង្រ មហាលាភ** ដែលមានទីតាំងស្ថិតនៅភូមិប៉ាក់ណាម ឃុំពង្រ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ រហូតមកដល់ពេលបច្ចុប្បន្ននេះគ្រួសារក្រីក្រចំនួន **១,២២៧គ្រួសារ** ( ស្មើនឹង ៦,០១២ នាក់ ) បានទទួលជំនួយបដិភាគ តភ្ជាប់បណ្តាញ និងបានប្រើប្រាស់ទឹកស្អាត។

**៥. គម្រោងបង្កើនន្ធូវភាពធន់នឹងអាកាសធាតុ** ( UNICEF )

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចុះកិច្ចព្រមព្រៀមជាមួយ អង្គការយូនីសេហ្វ លើគម្រោង «បង្កើននូវភាពធន់នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនរស់នៅក្នុងឃុំដែលមានហានិភ័យទៅនឹងអាកាសធាតុមួយចំនួន ដែលស្ថិតនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងស្រុកបូរីជលសាខេត្តតាកែវ» ៕



មជ្ឈមណ្ឌលភ្នំពេញ អគារF បន្ទប់២៦៩ ទន្លេបាសាក់ ចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ ០១៧/០៧០ ៧៩៩ ៣៣៧ , ០៩៧ ៧១៧ ៩៩៤៣, Email: info@cwa.org.kh, website: www.cwa.org.kh